# ទស្សនវិជ្ជាសង្គម និង ទស្សនវិជ្ជានយោបាយខ្មែរ តាមរយៈ រឿងធម្មបាលកុមារ

*ដោយ៖ លោក* **ឈុន ផាវ៉េង**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្តីផ្តើម

*រឿងធម្មបាលកុមារ ដែលគេច្រឡំហៅថា រឿងកបិលមហាព្រហ្ម គឺជាទេវកថាមួយដែលបានបង្កប់នូវខ្លឹមសារទស្សនវិជ្ជាសង្គមនិងនយោបាយខ្មែរយ៉ាងជ្រាលជ្រៅ។ រឿងនេះបាននិងកំពុងមានប្រជាប្រិយភាពខ្លាំងសម្រាប់ជនជាតិខ្មែរគ្រប់វ័យជាច្រើនសតវត្សរ៍មកហើយ។ រឿងនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃព្រលឹងអរិយធម៌ជាតិខ្មែរ។ រាល់ពេលពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរជារៀងរាល់ឆ្នាំ ជនជាតិខ្មែរតែងនិទានរំលឹកអំពី រឿងធម្មបាលកុមារ នេះ តិចឬច្រើននៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ក្នុងគោលបំណងដាស់សតិសម្បជញ្ញៈ មនសិការស្មារតីមនុស្សទាំងឡាយឱ្យបរិបូណ៌ទៅដោយព្រហ្មវិហារធម៌ ពោលគឺឱ្យចេះមេត្តា ករុណា មុទិតា និងឧបេក្ខា ដល់ មនុស្សសត្វគ្រប់វ័យ គ្រប់ប្រភេទ ដើម្បីជីវិតរស់នៅប្រកបដោយសេចក្តីសុខចម្រើន។*

## ១.រឿងធម្មបាលកុមារ[1]

*ក្នុងកាលដើម នៃកប្បនេះ មានបុរសម្នាក់ឈ្មោះ ធម្មបាល ជាបុត្រសេដ្ឋី ជាអ្នកមាន*



គេហទំព័រ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៖ *ពិធីបុណ្យចូលឆ្នាំខ្មែរ*, ផ្សាយថ្ងៃ សុក្រ ទី ១៧ ខែ មករា ឆ្នាំ ២០១៧។
http://www.mcfa.gov.kh/site/detail/25

*ចំណេះវិជ្ជាដ៏វិសេស រៀនចប់ចេះត្រៃវេទ តាំងពីអាយុបាន៧ ឆ្នាំ។ សេដ្ឋីបិតា បានសាងប្រាសាទឱ្យនៅទៀបដើមជ្រៃ១ ធំ នៅឆ្នេរទន្លេដែលជាទីនៅនៃបក្សីទាំងឡាយ។ ធម្មបាលកុមារនោះ បានចេះទាំងភាសាបក្សីទាំងពួងផង ហើយបានជាអាចារ្យសម្តែងមង្គលផ្សេងៗ ដល់មនុស្សទាំងពួង។ គ្រានោះមនុស្សលោករមែងរាប់អាន ព្រះមហា*

[1] *ពុទ្ធសាសនបណ្ឌិត្យ, ព្រះរាជពិធីទ្វាទសមាស, បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ១៩៦៩*

ព្រហ្ម[2] និង កបិលមហាព្រហ្ម[3] ១អង្គទៀតថាជាអ្នកសម្តែងមង្គលដល់មនុស្សទាំងពួង។ កាលកបិលមហាព្រហ្មជ្រាបពត៌មាននោះ ក៏មកសួរបញ្ហានឹងធម្មបាលកុមារ ៣ខ ដោយសន្យាទុកថាបើដោះប្រស្នាបាននឹងកាត់ក្បាលបូជាធម្មបាលកុមារ បើដោះមិនបាននឹងកាត់ក្បាលធម្មបាលកុមារវិញ។ ធម្មបាលកុមារសុំឱ្យបង្អង់ ៧ថ្ងៃ សិនដើម្បីគិតប្រស្នា លុះវេលាកន្លងទៅ ៦ថ្ងៃហើយក៏គិតប្រស្នានោះមិនឃើញ ដឹងខ្លួនថា ព្រឹកនេះនឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្មជាប្រាកដ ហើយ ដូច្នេះគួរអញរត់ទៅពាក់ពួនលាក់ខ្លួនឱ្យស្លាប់បង់ដោយខ្លួនឯងប្រសើរជាង ទើបចុះអំពីប្រាសាទទៅដេកពួននៅក្រោមដើមត្នោតមួយគូ ។ ដើមត្នោតនោះ សត្វឥន្ទ្រីញីឈ្មោលធ្វើសំបុកអាស្រ័យនៅ វេលាយប់ឥន្ទ្រីញីសួរឥន្ទ្រីឈ្មោលថាព្រឹកនេះយើងបានអាហារពីណាស៊ី (តែក្បួនខ្លះថាកូនឥន្ទ្រីសួរមេវា) ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងបានស៊ី សាច់ធម្មបាលកុមារ ដែលត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រីញីសួរថា ប្រស្នានោះដូចម្តេច? ឥន្ទ្រីឈ្មោលឆ្លើយថាវេលាព្រឹកសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថា នៅមុខហេតុនោះមនុស្ស ទាំងឡាយត្រូវយកទឹកលុបមុខ។ ខ ១ ទៀតថា ថ្ងៃត្រង់សិរីស្ថិតនៅទីណា? ត្រូវឆ្លើយថា នៅទ្រូង ហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងទ្រូង។ ខ ១ ទៀតថា វេលាល្ងាចសិរីស្ថិតនៅទីណា ? ត្រូវឆ្លើយថា នៅជើងហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងជើង។ ធម្មបាល កុមារបានឮដូច្នោះ ក៏ត្រឡប់ទៅប្រាសាទវិញ។ ព្រឹកឡើង កបិលមហាព្រហ្មមកដល់សួរប្រស្នា ធម្មបាលកុមារក៏ឆ្លើយដោះស្រាយតាមដែលបានឮមក កបិលមហាព្រហ្មទើបហៅធីតាទាំង៧នាក់ ដែលជាបាទបរិចារិកា[4] របស់ព្រះឥន្ទ្រ មកប្រាប់ថា ឥឡូវបិតាត្រូវកាត់ក្បាលបូជាធម្មបាលកុមារ តែបើដាក់ក្បាលនោះនៅលើផែនដី ក៏នឹងកើតជាភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាស ភ្លៀងក៏នឹងរាំង បើនឹងចោលក្នុងមហាសមុទ្រ ទឹកក៏នឹងរីងស្ងួតហួតអស់ទៅ ដូច្នេះសុំឱ្យកូនទាំង ៧ នាក់យកពានមកទទួលក្បាល ថាហើយក៏កាត់ក្បាល ហុចទៅឱ្យនាងទុង្សាដែលជាកូនច្បង នាងទុង្សា ទើបយកពានចូលទៅទទួលក្បាលបិតា ហើយហែប្រទក្សិណភ្នំព្រះសុមេរុ ៦០ នាទី ហើយក៏អញ្ជើញទៅប្រតិស្ឋានទុកក្នុង មណ្ឌបនៅក្នុងគុហាគន្ធមាលីភ្នំកៃលាស បូជាដោយគ្រឿងទិព្វផ្សេងៗ ព្រះវិស្សកម្មក៏និម្មិតរោងដ៏ហើយដោយ

[2]មហាព្រហ្ម តំណាងលទ្ធិព្រហ្មញ្ញសាសនា។

[3]កបិលមហាព្រហ្ម តំណាងលទ្ធិពុទ្ធសាសនាមហាយាន។

[4] បាទបរិចារិកា(ឬបាទបរិចាក) ជាស្ត្រីអ្នកបម្រើជិតជើង, ជាភរិយា, ជាស្ត្រីដែលស្វាមីត្រូវចិញ្ចឹម ឬជាប្រពន្ធ។

កែវ៧ប្រការ ឈ្មោះថា"ភគវតីសភា"[5] ឱ្យជាទីប្រជុំនៃទេវតា លុះដល់គម្រប់ ១ ឆ្នាំជាសង្ក្រាន្ត នាងទេពធីតាទាំង ៧ ក៏ផ្លាស់វេនគ្នាមកអញ្ជើញក្បាលកបិលមហាព្រហ្ម ចេញមកហែប្រទក្សិណភ្នំព្រះសុមេរុ[6]រាល់ៗឆ្នាំ ហើយត្រឡប់ទៅទេវលោកវិញ។

លុះគំរប់ឆ្នាំសង្ក្រាន្ត ទេពធីតាទាំង៧ ក៏ដូរសំវេនគ្នាហែក្បាលកបិលមហាព្រហ្ម ប្រទក្សិណភ្នំព្រះសុមេរុ រាល់ៗឆ្នាំរហូតមក[7] ។

## ២.សម្មតិកម្មនៃពាក្យគន្លឹះក្នុងរឿងធម្មបាលកុមារ

យើងសាកល្បងដាក់នូវសម្មតិកម្មមួយចំនួន ក្នុងគោលដៅស្វែងរកអំណោះអំណាងចាំបាច់គ្រប់គ្រាន់(ទឡ្ហីករណ៍) ដើម្បីឈានដល់សន្និដ្ឋានឱ្យសមស្រប។ ពេលនេះយើងស្នើនូវសម្មតិកម្មដូចតទៅ៖ **ក.មហាព្រហ្ម** គឺលទ្ធិព្រាហ្មណ៍សាសនា, **ខ.កបិលមហាព្រហ្ម** គឺលទ្ធិពុទ្ធសាសនាមហាយាន។ **គ.ធម្មបាលកុមារ** គឺលទ្ធិពុទ្ធសាសនាថេរវាទ។ **ឃ.កាត់ក្បាល** គឺការដកខ្លួនចេញ។ **ង.នៅក្រោមដើមភ្នោតមួយគូ** គឺទឹកដីខ្មែរដែលនិយមគោរពជំនឿជីវចលនៃជំនឿមេបា។ **ង.សត្តឥន្ទ្រី** (ឬឥន្ទ្រិយ) គឺអំណាចជាធំនៃការដឹងតាមអាយតនៈខាងក្នុងទាំង៦៖ ១.ចក្ខុន្ទ្រិយ(ភ្នែក); ២.សោតិន្ទ្រិយ(ត្រចៀក) ៣.ឃានិន្ទ្រិយ(ច្រមុះ) ៤.ជិវ្ហិន្ទ្រិយ(អណ្តាត) ៥.កាយិន្ទ្រិយ(កាយ) ៦.មនិន្ទ្រិយ(មនោ ឬ ចិត្ត)។ អាយតនៈខាងក្នុងទាំង៦ នេះជាធំក្នុងការទទួលដឹង។ **ច.វេលាព្រឹកសិរីស្ថិតនៅមុខ ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលុបមុខ** គឺមានន័យថា ក្នុងបឋមវ័យ(វ័យកុមារ) ជោគជ័យមង្គល សួស្តីលាភ ឥស្សរភាព តេជះ អំណាច សេចក្តីសុខចម្រើន ភ័ព្វព្រេងសំណាងល្អទាំងឡាយ ស្ថិតនៅលើរាងកាយប៉ែកខាងលើ ពោលគឺក្បាល ដែលជាប្រធាននៃសរីរាង្គកាយទាំងមូល ដែលក្នុងនោះមាន មាត់ អណ្តាត ត្រចៀក, ភ្នែក, ច្រមុះជាដើម។ ហេតុនេះគេត្រូវយកចិត្តទុកដាក់លើការអប់រំមនុស្សឱ្យមានសីលធម៌ និងចំណេះដឹងទាន់ខ្លួននៅក្មេង។ **ឆ.វេលាថ្ងៃត្រង់សិរីស្ថិតនៅទ្រូង ហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងទ្រូង** គឺមានន័យថា នៅមជ្ឈិមវ័យ(វ័យកណ្តាល ឬយុវវ័យ) ជាវ័យស្នេហា។ យុវវ័យគឺជាវ័យដែលត្រូវស្រឡាញ់ការងារ ជាវ័យស្នេហាបង្កបង្កើតគ្រួសារប្តីប្រពន្ធ ផ្តល់កំណើតនិងចិញ្ចឹមរក្សាកូន ដើម្បីបន្តពូជពង្សនិងនិរន្តរភាពសង្គម។ **ជ.វេលាល្ងាចសិរីស្ថិតនៅជើង ហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងជើង** គឺមានន័យថា នៅបស្ចិមវ័យ(វ័យចាស់) ជាវ័យ

[5] ភគវតីសាលា ជាផ្ទះ មន្ទីរ ឬរោងសម្រាប់ស្ត្រីអ្នកមានបុណ្យមានស័ក្តិធំទាំងពួង។

[6] សុមេរុ ភ្នំខ្ពស់ជាងភ្នំទាំងអស់ក្នុងសាកលលោក, ជាទីតាំងនៃត្រៃត្រិង្សស្ួគ៌ ដែលជាឋានរបស់ព្រះឥន្ទ្រ។

[7] ត្រឹង ងា(អ្នកស្រី), *អរិយធម៌ខ្មែរ(ថ្នាក់ទីបញ្ចប់)*, ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី៣, ១៩៧៤ ទំព័រ ២១០

ដើរចាកចេញពីតួនាទីទទួលខុសការងារសង្គម ដើម្បីទុកឱកាសដល់យុវជនជំនាន់ក្រោយ ដោយសន្តិវិធី ទៅរកកន្លែងស្ងប់ក្នុងជីវិតសមាធិ (គឺជីវិតចូលនិវត្តន៍)។ ***ឈ.យកពានមកទទួលក្បាល*** គឺការលើកតម្លៃព្រហ្មវិហារធម៌ មានមេត្តា ករុណា មុទិតា និងឧបេក្ខា។ ***ញ.គម្រប់១ឆ្នាំជាសង្ក្រាន្តនាងទេពធីតាទាំង ៧ ក៏ផ្លាស់វេនគ្នា*** គឺ៖១.ថ្ងៃអាទិត្យ ទុង្សាទេវី គ្រឿងអាភរណៈ ពណ៌ក្រហម សៀតផ្កាទទឹម គ្រឿងប្រដាប់កែវបទុមរាគ សោយផ្លែល្វា ដៃស្តាំកាន់កងចក្រ ឆ្វេងកាន់ខ្យងស័ង្ខ ពាហនៈ ឥន្ទ្រី។ ២.ថ្ងៃចន្ទ ទេវតានាម គោរាគទេវី គ្រឿងអាភរណៈ ពណ៌លឿងទុំ សៀតផ្កាអង្គាបុស្ស គ្រឿងប្រដាប់ កែវមុក្តា សោយតេលំ (ប្រេង) ព្រហស្តស្តាំកាន់ព្រះខ័ន ឆ្វេងកាន់ ឈើច្រត់ ពាហនៈ ព្យគ្ឃៈ (ខ្លា)។ ៣.ថ្ងៃអង្គារ ទេវតានាម រាក្សសាទេវី ពណ៌ស្វាយក្រម៉ៅ សៀតផ្កាឈូក គ្រឿងប្រដាប់ កែវមោរា សោយលោហិត(ឈាម) ដៃស្តាំកាន់ ត្រីសូល៍ ឆ្វេងកាន់ ដងធ្នូ ពាហនៈ សត្វសេះ។ ៤.ថ្ងៃពុធ ទេវតានាម មណ្ឌាទេវី ពណ៌ស៊ីលាប សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ កែវពិទូរ្យ សោយទឹកដោះសិប្បិ (ទឹកដោះស្រស់) ដៃស្តាំកាន់ម្ជុល ឆ្វេងកាន់ឈើច្រត់ ពាហនៈ សត្វលា។ ៥.ថ្ងៃព្រហស្បតិ៍ ទេវតានាម កិរិណីទេវី ពណ៌បៃតង សៀតផ្កាចំប៉ី គ្រឿងប្រដាប់ត្បូងមរកតសោយសណ្តែក ល្ង ព្រហស្តស្តាំកាន់ កង្វេរ ដំរី ឆ្វេងកាន់កាំភ្លោះបាញ់ ពាហនៈ ដំរី។ ៦.ថ្ងៃសុក្រ ទេវតានាម កិមិរ៉ាទេវី ទ្រង់ពណ៌ស សៀតផ្ការំចង់ សោយចេកណាំវ៉ា ព្រហស្តស្តាំកាន់ ព្រះខ័ន ឆ្វេងកាន់ ពិណ ពាហនៈ ក្របី ។ ៧.ថ្ងៃសៅរ៍ ទេវតានាមមហោទរាទេវី ទ្រង់ពណ៌ខៀវ សៀតផ្កាកណិកា គ្រឿងប្រដាប់ត្បូង និលរ័ត្ន សោយសាច់ទ្រាយ(ពពួក ក្ដាន់ ឈ្លូស) ស្តាំកាន់កងចក្រ ឆ្វេងកាន់ ត្រីសូល៍ ពាហនៈ ក្ងោក ។***ដ.កែវ៧ប្រការគឺ៖*** ១.សុវណ្ណ :(មាស) ២.រជត :(ប្រាក់) ៣.មុត្តា (គជ់ខ្យង) ៤.មណិ (កែវមណី) ៥.វេឡុរិយ:(កែវពិទូរ្យ, កែវភ្នែកឆ្មា) ៦.វជិរ:(ពេជ្រ) ៧.បវាឡ:(កែវប្រពាល)។ ***ឋ.ព្រះឥន្ទ្រ*** គឺអាទិទេពសំខាន់ទាំងក្នុងលទ្ធិព្រាហ្មណ៍ និងលទ្ធិពុទ្ធសាសនាថេរវាទ។ ព្រះឥន្ទ្រជាអ្នកចម្បាំង, ជាទេពបង្អុរទឹកភ្លៀង, ចូលចិត្ត សេពសុរា, ល្មោភកាមគុណ ប្រពន្ធច្រើន(ក្នុងនោះមានទេពធីតាជាបុត្រីកបិលមហាព្រហ្មទាំង៧ផងដែរ) និងមានស្រីស្នំច្រើនពាន់នាក់ទៀតនៅតែមិនស្កប់ស្កល់។ ព្រះឥន្ទ្រសោយរាជ្យនៅ ឋានសួគ៌ គឺភ្នំព្រះសុមេរុ។ ***ឌ.ទេវលោក*** គឺឋានទេវលោកទាំង៧ គឺ៖ ចាតុម្មហារាជិកា, តាវត្តិង្ស, យាមា, តុសិតា, និម្មានរតី, បរនិម្មិតវសវតី និងឋានដ៏ខ្ពង់ខ្ពស់មួយទៀតគឺឋានព្រហ្មលោក។ ឋានទាំង៧នេះរមែងបែងចែកបដិសន្ធិសត្វទៅតាមកម្លាំងបុញ្ញកម្មដែលខ្លួនបានសាងហើយ ។ តាមគម្ពីរធម្មបទបានបរិយាយថា៖

១.អ្នកណាឲ្យទាន ដោយប្រាថ្នាផលតបមកវិញយ៉ាងណាមួយក្នុងភពខាងមុខ កាលស្លាប់ហើយនឹងកើតជាទេវតាជាន់ចាតុម្មហារាជិកា ។ ២.អ្នកណាឲ្យទាន ដោយមិនប្រាថ្នាផលតបមកវិញក្នុងភពខាងមុខទេ គឺឲ្យដោយគិតថា ការឲ្យទានជាការល្អ កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់តាវត្តិង្ស ។ ៣.អ្នកណាឲ្យទាន ដោយគិតថា មាតាបិតា យាយ តា ធ្លាប់ធ្វើមកហើយ គួរធ្វើតទៅ មិនឲ្យខូចប្រពៃណី កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់យាមា ។ ៤.អ្នកណាឲ្យទានដោយមេត្តា ប្រាថ្នានឹងឲ្យអ្នកទទួលទាននោះមានសេចក្តីសុខ មិនមានសេចក្តីលំបាក កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់តុសិត ។ ៥.អ្នកណាឲ្យទាន ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ អ្នកឲ្យទានកន្លងមកពីកាលមុន កាល ស្លាប់ហើយ នឹងកើតជាទេវតាជាន់និម្មានរតី។ ៦.អ្នកណាឲ្យទានដោយឃើញថា កាលឲ្យទានហើយ នឹងធ្វើចិត្តឲ្យសោមនស្សកើតសេចក្តីជ្រះថ្លា កាលស្លាប់ហើយនឹងកើតជាទេវតាជាន់បរនិម្មិតវសវត្តី។ ៧.អ្នកណា ឲ្យទាន ដើម្បីជម្រះចិត្តឲ្យផូរផង់បានឈាន កាលស្លាប់ហើយ នឹងកើតក្នុងព្រហ្មលោក។ ការបំពេញទានដោយមេត្តាចិត្តគិតឱ្យអ្នកទទួលបានសុខ រួចចាកទុក្ខ ទាំងពួងទានរបស់លោកអ្នកនឹងទទួលបានផលច្រើនតាមកម្លាំងសទ្ធា។

យើងអាចសន្និដ្ឋានបានថា តាមដំណើររឿងធម្មបាលកុមារ, តួអង្គកបិលមហាព្រហ្ម ដែលតំណាងឲ្យពុទ្ធសាសនានិកាយមហាយាន បានដកខ្លួនចេញឈប់មានតួនាទីផ្សព្វផ្សាយគោលលទ្ធិរបស់ខ្លួនជាផ្លូវការ ជាសាធារណៈដូចមុនទៀតឡើយ ដោយប្រគល់តួនាទីឱ្យធម្មបាលកុមារដែលតំណាងឱ្យពុទ្ធសាសនានិកាយថេរវាទ ជាអ្នកមាននាទីជំនួសវិញ។

**៣.ប្រវត្តិនៃការផ្លាស់ប្តូរលទ្ធិសាសនានៅកម្ពុជា**

នៅមុននិងក្រោយសម័យអង្គរ សាសនាមានមុខងារយ៉ាងសំខាន់ក្នុងសង្គម និង នយោបាយខ្មែរ។ អ្នកដឹកនាំខ្មែរ មានជំនឿលើសាសនាមិនដូចគ្នាទេ ព្រះរាជាអង្គខ្លះកាន់លទ្ធិព្រាហ្មណ៍សាសនា និងខ្លះទៀតកាន់ព្រះពុទ្ធសាសនា។ ចំពោះលទ្ធិព្រាហ្មណ៍សាសនា មាននិកាយ៣ខុសគ្នា។ ព្រះរាជាខ្លះកាន់សាសនាឥសូរ ខ្លះកាន់សាសនាព្រះវិស្ណុ ខ្លះកាន់សាសនាព្រះព្រហ្ម។ ចំណែកពុទ្ធសាសនាមានព្រះរាជាខ្លះកានមហាយាន និងខ្លះនិកាយថេរវាទ។ នៅសម័យនោះសាសនាទាំងនេះសម្រាប់តែព្រះរាជានិងពួកអភិជនប៉ុណ្ណោះ មិនសូវជ្រួតជ្រាបចូលក្នុងស្រទាប់ទាបនៃសង្គមឡើយ ព្រោះប្រជាជនដែលនៅតែថែរក្សាជំនឿដើម គឺជំនឿលើអារក្សអ្នកតា ដោយគោរពដំបូថជាតំណាងជាដើម។

ពីស.វ.ទី៩ដល់១១ គណៈសិវនិយមមានឧត្តមភាពលើគណៈឯទៀតៗ ព្រោះព្រះរាជាភាគច្រើនបានចាត់ទុកថាជាសាសនានេះសម្រាប់រដ្ឋ។ ដោយការប្រារព្ធធ្វើពិធីទេវរាជ ព្រះរាជាមានឋានៈស្មើអាទិទេព(ព្រះឥសូរ) ហើយមានសិវលិង្គជាតំណាងតំកល់ក្នុងប្រាសាទភ្នំ។ ប៉ុន្តែក្នុងរយៈពេលខាងលើនេះគេ បានសង្កេតឃើញថា ព្រះរាជាទាំងឡាយតែងបានយកព្រះហឫទ័យទុកដាក់ និងជួយឧបត្ថម្ភចំពោះ សាសនាឯទៀតដែលបានរួមរស់ជាមួយគ្នាយ៉ាងសុខដុមរមនា ដែលមានសិលាចារិក និងរូបបដិមាអាចបញ្ជាក់បានយ៉ាងបរិបូណ៌ លើកលែងតែក្នុងរជ្ជកាលរបស់ព្រះបាទឧទយាទិត្យវរ្ម័នទី២ ដែលមានការបះបោរបីលើក ហើយដែលគេឃើញពួកបះបោរដើរវាយកំទេចសិវលិង្គ និង ទេវបដិមា ចោល។ នៅស.វទី១២ គណៈវិស្ណុនិយមត្រូវបានព្រះបាទសូរ្យវរ្ម័នទី២ គោរពរាប់អានសម្បើមដូចមានប្រាសាទអង្គរវត្តជាសក្ខីភាពស្រាប់។[8] ...តពីនេះទៅ គេឃើញថាពុទ្ធសាសនាមហាយានដែលបាននាំចូលមកតាំងពីសម័យចេនឡា(ស.វទី៤) ហើយដែលបានព្រះបាទសូរ្យវរ្ម័ទី១កាន់ម្តងរួចហើយ(ស.វ.ទី១១) ត្រូវបានព្រះរាជាលើកតំកើងជាសាសនាសម្រាប់រដ្ឋតែម្តង ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧។ ប្រាសាទបាយ័ន ដែលព្រះអង្គសាងឡើង នៅមានទ្រង់ទ្រាយជាប្រាសាទភ្នំ ហើយស្ថិតនៅកណ្តាលរាជធានីដដែល តែរូបសំណាក ព្រះរាជាគឺជាពុទ្ធបដិមា ទៅវិញ(ពុទ្ធរាជ)។ ហេតុអ្វីបានជាមានការប្រែប្រួលយ៉ាងនេះ? ត្រង់នេះគួរគប្បីជ្រាបថាការវាយយកបានក្រុងអង្គរដោយទ័ពចាមនៅគ.ស.១១៧៧ ហើយជាលើកទី ១ ផងនោះជាអន្ទងមួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ។ ប្រជារាស្ត្រទំនងជាចង់លែងជឿទៅលើប្រសិទ្ធភាព លទ្ធិនេះទៀតហើយ ក៏ប៉ុន្តែពួកព្រាហ្មណ៍ជាបរិវារ នៅមានឥទ្ធិពលខ្លាំងក្លាណាស់នៅឡើយ ទើបព្រះបាទជ័យវរ្ម័នទី៧ទ្រង់ឈ្វេងយល់ថាត្រូវតែរក្សាទុករបស់ចាស់ខ្លះ(មិនអាចកំចាត់ចោលភ្លាមៗបានទេ) ហើយយករបស់ថ្មីខ្លះមកប្រើ ដើម្បីឱ្យមានសង្ឃឹមដល់ប្រជារាស្ត្រដោយផ្សំធាតុសិវនិយមខ្លះ (ប្រាសាទភ្នំ) និង ពុទ្ធនិយមខ្លះ (ពុទ្ធរាជ)។ ដូច្នេះ យើងឃើញថាពុទ្ធសាសនាមហាយានបានមកដល់ទាន់ពេលវេលា ដើម្បីស្រោចស្រង់ជាតិ ឱ្យមានពន្លឺឡើងវិញ ក្រោយព្រឹត្តិការណ៍១១៧៧ ដែលព្រះបាទជ័យ វរ្ម័នទី៧ ហ៊ានយកលទ្ធិនេះ មកប្រើ ព្រោះពេលនោះពុទ្ធសាសនិក ក៏មានកាន់តែច្រើនណាស់ហើយ ហើយម្យ៉ាងទៀតលទ្ធិនេះជាលទ្ធិបែបមនុស្សនិយម មានទំនោរទោរទៅរកជីវភាពប្រជារាស្ត្រ

[8] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ១១៣

ទូទៅដូចរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន ជាសក្ខីភាពស្រាប់ ហើយដើម្បីបង្ហាញឱ្យឃើញនូវព្រះហឫទ័យមេត្តាករុណាចំពោះប្រជារាស្ត្រនេះ ព្រះអង្គទ្រង់បានកសាងមន្ទីរពេទ្យ ១០២ សម្រាប់ជនទាំង៤វណ្ណៈ ចូលព្យាបាលជម្ងឺបានដូចៗគ្នា។ ទាំងនេះសឱ្យឃើញថា នៅចំពោះប្រជារាស្ត្រ លទ្ធិពុទ្ធសាសនាមហាយាន មានសមត្ថភាពមិនចាញ់លទ្ធិទេវរាជទេ គឺមានសមត្ថភាពការពារស្រោចស្រង់និងបំរើរាស្ត្របានដូចគ្នា។ តែអកុសល ការផ្លាស់ប្តូរសាសនានៅតែមានបន្តទៅទៀត។ ព្រះបាទជ័យវរ្ម័នទី៨ត្រឡប់ទៅរកសិវនិយមវិញដែលជាហេតុបណ្តាលឱ្យមានប្រតិកម្មយ៉ាងខ្លាំងក្លាពីពួកព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនា(មហាយាន)រហូតដល់មានការវាយកំទេចឬកោសលុបព្រះពុទ្ធបដិមាចោល។ ស្ថានការណ៍បែបនេះទំនងជាមានសភាពពុំរ៉ែរហូតដល់បដិវត្តន៍នាយត្រសក់ផ្អែមដែលបានយកពុទ្ធសាសនាហីនយានមកជំនួសជាស្ថាពររហូតមកដល់សព្វថ្ងៃនេះ។[9]

ទំនាស់ក្នុងផ្លូវសាសនានេះមានយូរណាស់មកហើយ គឺតាំងពីក្នុង រជ្ជកាលឧទយាទិត្យវរ្ម័នទី២ ម៉្ងេះ(១០៥០-១០៦៦) ដោយនៅពេលនោះ គេឃើញមានការបះបោរបីលើក ហើយក្នុងចលនាទាំងនោះ ពួកបះបោរបានវាយកំទេចសិវលិង្គ និងបដិមាផ្សេងៗខាងព្រាហ្មណ៍សាសនាផង។ ឯពុទ្ធសាសនាឃើញថាមានការចំរើនលូតលាស់កាន់តែខ្លាំង ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទធរណីន្ទ្រវរ្ម័នទី២ (១១៥៥-?) និងព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨?) រហូតដល់មាន ប្រតិកម្មយ៉ាងខ្លាំងក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៨ ពីសំណាក់អ្នកកាន់ពុទ្ធសាសនានិងសាសនាព្រាហ្មណ៍។ ដូច្នេះយើងឃើញថា វិបត្តិខាងសាសនាកាន់តែរីកធំឡើងដោយបន្ទាប់ពីនោះមានស្តេចខ្លះក៏ត្រឡប់ទៅកាន់ពុទ្ធសាសនាវិញ ហើយជាពុទ្ធសាសនាថេរវាទថែមទៀត ដែលព្រះអង្គម្ចាស់តាមលិន្ទបាននាំចូល ស្រុកខ្មែរប្រហែលតាំងពីរជ្ជកាលឥន្ទ្រវរ្ម័នទី២មកម៉្លេះ ហើយក៏មានស្តេចខ្លះត្រឡប់ទៅកាន់សាសនាព្រាហ្មណ៍វិញដែរ រហូតដល់រជ្ជកាលរបស់នាយត្រសក់ផ្អែម និងកូនចៅរបស់គាត់ដែលសោយរាជ្យតរៀងមក ទើបស្តេចខ្មែរកាន់ជាប់តែពុទ្ធសាសនារហូតដល់សព្វថ្ងៃ។ ត្រង់នេះហើយជាហេតុនាំឱ្យអ្នកប្រវត្តិសាស្ត្រខ្លះយល់ថា កាលដែលនាយត្រសក់ផ្អែមធ្វើគត់ស្តេច ហើយបាននាម៉ឺនសព្វមុខមន្ត្រីលើកឱ្យឡើងសោយរាជ្យ ជាបដិវត្តន៍ដណ្តើមយកអំណាចនយោបាយ និងអំណាចសាសនាដែលជាប់គ្នា ព្រោះក្នុងសម័យ

[9] ត្រឹង ង៉ា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ.ស. ១៩៧៣ ទំព័រ ១១៤

នោះអំណាចទាំងពីរស្ថិតនៅក្នុងការកាន់កាប់របស់ព្រះមហាក្សត្រទាំងអស់។[10]



## ៤.ព្រះព្រហ្មក្នុងលទ្ធិព្រាហ្ម

ព្រះព្រហ្ម ជាអាទិទេពមួយអង្គក្នុងចំណោមអាទិទេពទាំងបីក្នុង ព្រហ្មញ្ញសាសនា។ នៅក្នុងព្រហ្មញ្ញសាសនា ទ្រឹស្តីត្រីមូ៌តិ ជាលទ្ធផលនៃការបង្រួបបង្រួមអាទិទេពដែលមានឥទ្ធិពល។

ដើមឡើយ បរិស័ទដែលមានភក្តីចំពោះអាទិទេពខ្លួនបានប្រយុទ្ធការពារអាទិទេពរបស់ខ្លួនយ៉ាងប្តូរផ្តាច់រហូតបណ្តាលឱ្យមនុស្សសត្វរងទុក្ខវេទនាហិនហោចខ្ទោចផ្សារក្នុងសង្គ្រាមដើម្បីបូជាការពារអាទិទេពរបស់ខ្លួនអស់រយៈពេលដ៏យូរ និងស្លាប់អស់ជាច្រើនឥតគណនា។

ទីបំផុត បានទទួលព្រមថា ព្រះត្រីមូ៌តិ គឺអវតារតំណាងឱ្យអាទិទេពទាំងបី៖ ក.ព្រះព្រហ្ម ទេពបង្កើតលោក ខ.ព្រះវិស្ណុ ទេពការពារ និងថែរក្សាលោក គ.ព្រះសិវ ទេពបំផ្លាញលោក និងបង្កើតលោកឡើងវិញ។

មាននិទានថា ព្រះព្រហ្ម ទ្រង់បានបង្កើតផែនដីតាមរយៈការនិមិត្តនៅស៊ុតមាសមួយ ដែលហោះអណ្តែតនៅក្នុងចក្រវាឡ អស់១ម៉ឺនកល្ប (៤,៥៤ពាន់លានឆ្នាំ) ហើយស៊ុតនោះទ្រង់បានបំបែកវាជាពីរផ្នែក៖ ទី១ ក្លាយមេឃ  ទី២ក្លាយជាផែនដី។ ទ្រង់បង្កើតឱ្យមានធម្មជាតិ និង សត្វរស់នៅ។ រាប់រយពាន់ឆ្នាំ បន្ទាប់មកក៏បង្កើតឱ្យមានសការៈពីរ គឺ ពួកយក្ស និង ពួកស្វា រមែងធ្វើចម្បាំងនិងគ្នាមិនចេះចប់មិនចេះហើយ បន្ទាប់មកការវិវឌ្ឍន៍ចុងក្រោយរបស់ពួកស្វា បានក្លាយខ្លួនជាអំបូរមនុស្ស ដែលបែងចែកជា ២ភេទ ភេទប្រុស និង ភេទស្រី ដែលប្រុសហៅថាបុមៈ ស្រីហៅថាវិរដ្ឋា។ អំបូរមនុស្សបានរួមរស់ប្រវេណីជាមួយគ្នាកាន់តែច្រើនឡើងៗ កើតជាពូជមនុស្សពាសពេញពិភពលោក។ ព្រះព្រហ្ម ជាបង្កើតមនុស្ស និងបែងចែកមនុស្សក្នុងវណ្ណៈបួនផ្សេងគ្នាគឺ៖ ១.វណ្ណៈព្រាហ្មណ៍ ជាវណ្ណៈខ្ពស់បំផុតកើតពីព្រះឱស្ឋ (មាត់) របស់ព្រះព្រហ្ម ជាអ្នកថែរក្សា និងនាំពាក្យរបស់អាទិទេព។ ពួកព្រាហ្មណ៍ស្លៀកពាក់ស មានសិទ្ធិរៀនសូត្រគម្ពីរវេទគ្រប់បែបយ៉ាង។ ២.វណ្ណៈក្សត្រ កើតពីព្រះហស្តរបស់ព្រះព្រហ្ម ជាអ្នកគ្រប់គ្រងប្រទេស ជាអ្នកចម្បាំង ព្រមទាំងរៀនយុទ្ធវិធី

---

[10] ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ ១០៥

នានាផង។ វណ្ណៈក្សត្រស្មៀកពាក់ក្រហម ជានិមិត្តរូបនៃសេចក្តីក្លាហាន។ ៣.វណ្ណៈវៃស្យ (ឬវេស្សៈ) ជាវណ្ណៈកណ្តាល កើតពីភ្លៅរបស់ព្រះព្រហ្ម ដែលមានចំនួនភាគច្រើនក្នុងសង្គមជាប្រជាពលរដ្ឋទូទៅមានសិល្បករ សិប្បករ កសិករ ពួកឈ្មួញ ជាដើម។ វណ្ណៈវៃស្យស្មៀកពាក់ពណ៌លឿង។ ៤.វណ្ណៈសូទ្រ ជាវណ្ណៈទាបបំផុតក្នុងសង្គម កើតពីបាតជើងរបស់ព្រះព្រហ្ម ជាខ្ញុំបម្រើគេ ជាទាសករ ស្មៀកពាក់ពណ៌ខ្មៅ។ លក្ខណៈពិសេសសម្គាល់ព្រះព្រហ្មក្នុងលទ្ធិព្រាហ្មណ៍សាសនាគឺមាន៖ ១.ព្រះភ័ក្រ្ត៤ ព្រះហស្ត៤ ដោយមានកាន់កេតណភ័ណ្ឌ ៤យ៉ាងមានដូចជា ក.គម្ពីរវេទ ខ.ស្វាបព្រា គ.ថូទឹក និង ឃ.ខ្សែរផ្កាំ។ ២.រាងកាយសម្បុរពណ៌ផ្កាឈូកស្រាល ចំពោះយានជំនិះរបស់ព្រះព្រហ្មគឺ៖ ផ្កាឈូក១ពាន់ស្រទាប់ និងសត្វហង្ស ហើយព្រះព្រហ្ម ប្រថាប់នៅលើហង្សក្នុងទម្រង់លក្ខណៈចេញច្បាំងតែប៉ុណ្ណោះ។ ព្រះភ័ក្រ្តទាំង៤របស់ព្រះព្រហ្ម៖ ក.ព្រះភ័ក្រ្តខាងកើតតំណាងឱ្យកំណើតសត្វលោក។ ខ.ព្រះភ័ក្រ្តខាងលិច តំណាងឱ្យការវិលស្លាប់របស់សត្វលោក។ គ.ព្រះភ័ក្រ្តខាងជើង តំណាងឱ្យដួងព្រលឹង។ ឃ.ព្រះភ័ក្រ្តខាងត្បូង តំណាងឱ្យភាពបរិសុទ្ធ។ តាមកំណើតរបស់ព្រះព្រហ្មដែលកើតពីផ្កាឈូកមានព្រះភ័ក្រ្តចំនួន៥ តែព្រះភ័ក្រ្តទី៥ត្រូវបាន ព្រះឥសូរ ឬ ព្រះសីវៈកាត់បំផ្លាញចោលនៅពេលដែលប្រព្រឹត្តកំហុសរំលោភកូនខ្លួនឯង។ ព្រះព្រហ្មមានមហេសី២អង្គមានព្រះនាមថា "សាវិទ្រី" និង "ព្រះម៉ែសារ៉ាវត្តី" ដែលមានកំណើត តផុសចេញពីទឹកស្រះព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៦ ជាទេពធីតាតំណាងឱ្យដូរ្យតន្រ្តី និងសិរីសួស្តី។ ព្រះព្រហ្ម ក្នុងលទ្ធិព្រាហ្មណ៍សាសនាមានបុត្រា២អង្គ និង បុត្រី១អង្គគឺ៖ ១.ព្រះព្រហ្មទសក្ស (ទោះក្សៈ) ជាព្រហ្មមានពន្លឺ១០ពណ៌ និងមានព្រះឱសថទិព្វ គង់នៅឋានព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៥។ ២.ព្រះព្រហ្មភ៌គុ(ភរគុ) ជាអទិទេពតំណាងឱ្យអំណាចរបស់ឋានសួគ៌ទាំងអស់ គង់នៅឋានព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៤។ ៣.កូនស្រី ព្រះនាម ទេពធីតាសំធ្យា ឬ សន្ធិយា គង់នៅឋានព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៣ ។

ព្រះព្រហ្មបានប្រព្រឹត្តកំហុសធំ២យ៉ាង៖ ១.ទុច្ចរិតបន្ទំយកផ្កាកិកីពីឋាននរកកុហក់ថាជាសរសេរភ្លើង ២.ចាប់រំលោភទេពធីតាសំធ្យា ដែលជាបុត្រីបង្កើតរបស់ខ្លួនដោយព្រួញកាមទេព។

### ៥.ទ្រឹស្តីនៃលទ្ធិពុទ្ធសាសនាមហាយាន

ព្រះព្រហ្ម ក្នុងជំនឿពុទ្ធសាសនាមហាយាន មានឈ្មោះថា អវលោកេស្វរៈ។ យើងសង្កេតឃើញថា ទិដ្ឋភាពរួមនៃប្រាសាទបាយ័ន(អ្នកខ្លះហៅថា ប្រាសាទព្រហ្មបាយ័ន) និង ក្លោងទ្វារនៃទី

ក្រុងអង្គរធំ ដែលមានរូបព្រហ្មមុខបួន និង ចម្លាក់តំណាងព្រះភ័ក្ត្រនៃព្រះពោធិសត្វអវលោកេស្វរៈ នៅប្រាសាទតាសោម ដែលគេហៅថា មុខព្រហ្មមុខបួន។ ព្រហ្ម បែរមុខទៅតាមទិស ទាំង៤ ដំណាងឲ្យធាតុទាំង៤ ដែលមានខ្យល់ ទឹក ភ្លើង និងធរណី។ អាចបញ្ជាក់បានថា រូបព្រហ្មមុខ៤ នៅប្រាសាទបាយ័នមិនមែនជាព្រះព្រហ្មនៃព្រហ្មញ្ញសាសនាទេ គឺព្រះភ័ក្ត្រនៃព្រះពោធិសត្វ អវលោកេស្វរៈ។ រូបព្រហ្មមុខបួននេះក៏តំណាងឲ្យស្តេចព្រះបាទជ័យវរ្ម័នទី៧ ផងដែរ ព្រោះព្រះអង្គប្រកាស យកលទ្ធិពុទ្ធរាជ ដែលគេត្រូវចាត់ទុកជាព្រះពុទ្ធពោធិសត្វផង និង ជាស្តេចផែនដីផង។ ប្រាសាទបាយ័នកសាងឡើង ដើម្បីឧទ្ទិសថ្វាយព្រះពោធិសត្វ លោកេស្វរៈមានមុខ៤ ជាទីសំអាងក្នុងលទ្ធិព្រះពុទ្ធសាសនាមហាយាន។ មានអាថ៌កំបាំងនៃចំនួនដ៏ច្រើនលើសលុបរបស់ព្រះកេសនៃព្រះព្រហ្មមុខ នៅលើប្រាសាទបាយ័ន។ តាមពិតទៅបើសំអាងលើពុទ្ធប្រវត្តិរឿងដំណាលថា ព្រះពីដើមធ្លាប់សោយរាជ្យជាស្តេចចក្រពត្តិ កាន់បាទសូមទានគេ ហើយគេឥតគោរព ព្រះអង្គសម្តែងបដិហា កើតជាព្រះពុទ្ធ មួយអង្គ អណ្តែតពេញអាកាស។ និមិត្តរូបស៊ីជម្រៅឥតគណនា គឺអំណាចមហិទ្ធិឫទ្ធិបុណ្យបារមីដ៏លើសលប់គ្មានត្រើយត្រាន្តរបស់ព្រះលោកេស្វរៈ ដែលប្រកបដោយព្រហ្មវិហារធម៌ទាំង៤ ដ៏មហាប្រសើរសម្រាប់សត្វលោក។ ព្រះពោធិសត្វនៃពុទ្ធសាសនាមហាយានដ៏មានប្រជាប្រិយ៍នាសម័យបាយ័ន មានដូចជា៖ វជ្របាណិ, វជ្រធរ និងព្រះអមិតាភៈ។ តាមរយៈចម្លាក់ ព្រហ្ម នាប្រាសាទបាយ័ន ដែលសាងសង់ ដោយព្រះបាទ ជ័យវរ្ម័នទី៧ ក្នុងការផ្សារភ្ជាប់សាសនាព្រហ្មណ៍ ទៅនិង ពុទ្ធសាសនា ក្នុងគោលគំនិតនៃការបង្រួម ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ឱ្យក្លាយជាសាសនាតែមួយ តាមរយៈអាវតារ បែងភាគរបស់ព្រហ្ម ដែលមានឈ្មោះថា "អវតារ លោកកេស្វរៈ" (Avatar Lokesvara) ដែលប្រែថា ព្រះដ៏មានព្រះភាគ និង មានន័យថា ព្រះដ៏ចម្រើន។ ការសំយោគបែបនេះ ដោយសារព្រះអង្គចង់ឲ្យប្រជារាស្ត្រ ខ្មែរដែលមានជំនឿលើសាសនាផ្សេងគ្នា រស់នៅដោយសុខសាន្ត ដោយសន្តិភាព ក្រោមការគ្រប់គ្រងរបស់ទ្រង់។ ការដែលមានព្រះភ័ក្របួន ឬ មុខបួន គឺតំណាងឱ្យ ព្រហ្មវិហារធម៌ទាំង៤៖ មេត្តា ករុណា មុទិតា និង ឧបេក្ខា។ ក.មេត្តា (ឬ មេត្រី) គឺការស្រឡាញ់រាប់អានរាប់អានមនុស្សសត្វ ដោយមិនរើសអើង។ ខ.ករុណា គឺការអាណិតអាសូរអ្នកដែលមានទុក្ខលំបាក។ គ.មុទិតា គឺការទន់ទោរ ឬអបអរសាទរ ត្រេកអររីករាយ ចំពោះសេចក្តីសុខចម្រើន របស់អ្នកដទៃ ដោយមិនមានចិត្តច្រណែននិន្ទាឈ្នានីស។ ឃ.ឧបេក្ខា

*គឺការមិនលម្អៀងដោយអគតិណាមួយគឺមិនវិនិច្ឆ័យដោយទោសាគតិ, ឆន្ទាគតិ, ភ័យាគតិ, លោភាគតិជាដើម។ និកាយមហាយានយល់ថាករុណា គឺជាគុណធម៌ខ្ពស់បំផុត ដែលត្រូវជំរុញឱ្យមានការប្រតិបត្តិក្នុងពិភពលោក និងក្នុងចំណោមសហគមន៍ទូទៅ។ គេជឿថាពុទ្ធនៅតែជាព្រះពោធិសត្វ ដែលចាំជួយមនុស្សលោកបាននៅពេលដែលគេគោរពនិងស្នើសុំបួងសួង។*

*និកាយមហាយានជាយាន ទៅកាន់គោលដៅត្រឹមព្រះពោធិសត្វ អាចជួយណែនាំប្រោសសត្វបានទៅកាន់ឋានទេវលោកបានច្រើន។ និកាយនេះគោរពប្រតិបត្តិតាមលទ្ធិគ្រូអាចារ្យរបស់ខ្លួនជាធំ ពុំមែនតាមពុទ្ធឱវាទទាំងស្រុងទេ។ រហូតដល់សព្វថ្ងៃប្រទេសដែលនិយមនិកាយមហាយានមានដូចជា ចិន វៀតណាម ជប៉ុន ទីបេ ជាដើម។*

### ៦.ទ្រឹស្ដីនៃលទ្ធិពុទ្ធសាសនាថេរវាទ

*ការប្រឹងប្រែងរបស់និកាយថេរវាទគឺនាំបុគ្គល ទៅកាន់ការត្រាស់ដឹងប្រឹងប្រែងដើម្បីគតិបណ្ឌិត ផ្ដោតលើការសមាធិ ហើយទាមទារឱ្យបុគ្គលមានការលះបង់ខ្ពស់ ដូចជា បួសជាព្រះសង្ឃ ដូនជី ដើរតាមការបង្រៀនរបស់ព្រះពុទ្ធ។ និកាយពុទ្ធសាសនាថេរវាទ កំណត់ថាព្រះពុទ្ធសមណៈគោតមបានចូលបរិនិព្វានហើយ ព្រះអង្គមិនទទួលយកការបន់ស្រន់របស់មនុស្សលោកឡើយ។ អ្វីដែលអាចជួយមនុស្សបាន គឺពុទ្ធឱវាទដែលមានចែងទុកក្នុងគម្ពីរព្រះត្រៃបិដក ដែលពុទ្ធបរិស័ទត្រូវប្រតិបត្តិដោយខ្លួនឯង (អត្តា ហិ អត្តនោ នាថោ) ដើម្បីសេចក្ដីសុខចម្រើន។ គោលធម៌ប្រតិបត្តិសំខាន់គឺ«បញ្ញា-សីល-សមាធិ» ឬ «អដ្ឋង្គិកមគ្គ»។ ក.បញ្ញា (សម្មាទិដ្ឋិ , សម្មាសង្កប្បៈ)ខ.សីល(សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ)។ គ.សម្មាធិ(សម្មាវាយាម, សម្មាសតិ, សម្មាសមាធិ)។*

***១.សម្មាទិដ្ឋិ*** *(ការមានទស្សនៈត្រូវ បានដល់ការស្គាល់ច្បាស់នូវអរិយសច្ចៈ៤)។* ***២.សម្មាសង្កប្បៈ*** *(ការគិតត្រូវ បានដល់ការរិះរកផ្លូវចេញចាកទុក្ខ និងត្រិះរិះពីនាមរូបំ អនិច្ចំ ទុក្ខំ អនត្តា ជាដើម)។* ***៣.សម្មាវាចា*** *(ការនិយាយត្រូវបានដល់និយាយផ្ដល់ប្រយោជន៍ដល់អ្នកស្ដាប់ ជៀសវាងសំដីកុហក់បោកប្រាស់ ញុះញង់ បំបែកបំបាក់ចាក់ដោត ជៀមដាមរឡេះរឡោះឥតប្រយោជន៍)។* ***៤.សម្មាកម្មន្តៈ*** *(ការធ្វើប្រព្រឹត្តអំពើសកម្មភាពត្រឹមត្រូវ បានដល់ ការមិនសម្លាប់ជីវិត មិនលួចប្លន់ មិនផិតក្បត់ មិនសេពគ្រឿងញៀនស្រវឹង និងត្រូវដេកដើរឈរអង្គុយឱ្យបានសមស្រប)។* ***៥.សម្មាអាជីវៈ*** *(ការចិញ្ចឹមជីវិតត្រូវបានដល់ មិនលក់គ្រឿងអាវុធ គ្រឿងញៀនស្រា មិនបើកបនល្បែងស៊ីសង បនពេស្យា និងត្រូវចេះប្រមាណក្នុងការបរិភោគ សេពមេថុន និងធ្វើការងារមិនច្របូកច្របល់)។* ***៦.សម្មាវាយាមៈ*** *(ការព្យាយាមត្រឹមត្រូវ បានដល់ការព្យាយាមលះបង់អំពើអកុសល សន្សំអំពើល្អ រក្សាអំពើល្អឱ្យស្ថិតនៅគង់វង្ស និងសាងគុណធម៌បន្ថែម)។* ***៧.សម្មាសតិ*** *(ការមាន*

សតិរលឹកត្រឹមត្រូវ បានដល់មានសតិសម្បជញ្ញភ្ញាក់រលឹកនូវការដែលកំពុងធ្វើ កុំភ្លាត់ឡប់សតិមិនដឹងធ្វើអ្វី ហើយជារឿយៗ សតិតាមទាន់នូវការពិនិត្យមើលអកុសលចេតសិក ជាដើម)។ **៨.សម្មាសមាធិ** (ការធ្វើចិត្ត ឬការតាំងចិត្តត្រឹមត្រូវ បានដល់ការទម្លាប់ចិត្តឱ្យរឹងមាំក្នុងការគិតពិចារណា ដើម្បីសម្រេចគោលបំណងណាមួយ ដូចជាការយល់ដឹងអំពីខ្លួនឯង អំពីជីវិត និងយល់ដឹងអំពីអ្នកដទៃ។

ការប្រតិបត្តិតាមអដ្ឋង្គិកមគ្គនេះ អាចនាំដល់មគ្គផលនិព្វាន តាមឧប្បនិស្ស័យរៀងៗខ្លួនគឺមិនបន់ស្រន់សុំជំនួយពីព្រះពុទ្ធឬ ទេវតាណាមួយឡើយ។ ប្រទេសដែលនិយមនិកាយថេរវាទ មានដូចជា កម្ពុជា ថៃ ឡាវ ស្រីលង្កា ប៉ាល់ជាដើម។

## ៧.និន្នាភាពនៃពុទ្ធសាសនាក្នុងសង្គមខ្មែរបច្ចុប្បន្ន

សម្រាប់ពលរដ្ឋខ្មែរពុំដែលមានទំនាស់ដោយសារតែមានជំនឿសាសនាខុសគ្នា ឡើយ លើសពីនេះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងថា «ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀតដល់ សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ»។ ក្នុងន័យនេះ ស្ថានប័នរដ្ឋជាអ្នកទទួលខុសត្រូវការពារព្រះពុទ្ធសាសនាដោយសារមិនបានបញ្ជាក់អំពីការ

ចិត្តទុកដាក់អំពីនិកាយពុទ្ធសាសនាមហាយានឬថេរវាទឡើយ ដែលជាឱកាសសម្រាប់និកាយកាយទាំង២ កំពុងតែមានការប្រកួតប្រជែងរវាងនិកាយទាំងពីជាយថាហេតុ។ មានអ្នកប្រាជ្ញខាងថេរវាទមួយចំនួនបានប្រើប្រាស់ជីវិតរបស់លោកខិតខំពន្យល់ពុទ្ធបរិស័ទតាមពុទ្ធោវាទ តាមទ្រឹស្តីនិកាយថេរវាទ ប៉ុន្តែទោះយ៉ាងណាក៏មិនអាចជួយមនុស្សក្នុងសង្គមខ្មែរឱ្យចេញចាកពីឥទ្ធិពលនៃលទ្ធិពុទ្ធសាសនាមហាយាននិងព្រហ្មណ៍សាសនាបានច្រើនដែរ ព្រោះព្រះសង្ឃនិងគ្រូធម៌ មួយចំនួនដែលជ្រកក្រោមផ្លាកពុទ្ធថេរវាទ បាននិងកំពុងព្យាយាមពន្យល់បរិស័ទតាមការយល់ឃើញរបស់ខ្លួនយ៉ាងសកម្មនិងយ៉ាងប៉ិនប្រសប់ទៀតផង។ ប្រសិនបើស្ថានភាពនេះនៅតែបន្តកើតមាន ប្រហែលជាសង្គមខ្មែរបច្ចុប្បន្ន នឹងវិលទៅរកការគោរពបូជាពុទ្ធសាសនាមហាយានជាផ្លូវការវិញជាមិនខាន។ នេះជាសម្មតិកម្មមួយទៀតដែលត្រូវស្វែងរកទឡ្ហីករណ៍ដើម្បីសន្និដ្ឋាន។

## សេចក្តីសន្និដ្ឋាន

តាមរយៈដំណើររឿង និងខ្លឹមសារ ដែលបង្កប់ក្នុង រឿងធម្មបាលកុមារ និងយោងតាមតថភាពប្រវត្តិសាស្ត្រស្តីអំពីការផ្លាស់ប្តូរនៃលទ្ធិសាសនានៅកម្ពុជា ដូចដែលបានបង្ហាញខាងលើ យើងអាចទាញសេចក្តីសន្និដ្ឋានថា សម្មតិកម្មដែលយើងបានលើកយកមកបង្ហាញខាងលើ

*គឺអាចជាមូលដ្ឋានក្នុងការឆ្លុះបញ្ចាំងអំពីទម្រង់និងខ្លឹមសារពិតនៃទស្សនវិជ្ជាខ្មែរ ដែលពលរដ្ឋនិងអ្នកដឹកនាំអាចទទួលយកមកអនុវត្តក្នុងជីវភាពប្រចាំថ្ងៃតាមការយល់ឃើញរៀងៗខ្លួន។ ចំពោះបរិបទ បច្ចុប្បន្ន ពលរដ្ឋខ្មែរមានសិទ្ធិ ជ្រើសរើស ឬមិនជ្រើសរើសយកទស្សនៈនៃលទ្ធិសាសនាណាមួយសម្រាប់ជាមាគ៌ារស់នៅ ក៏បាន កុំឱ្យតែបំពានដោយកាយវាចា បៀតបៀនជំនឿលទ្ធិរបស់អ្នកដទៃ។ ទាំងលទ្ធិព្រាហ្មណ៍ សាសនា, លទ្ធិពុទ្ធសាសនាមហាយាន និងពុទ្ធិសាសនាថេរវាទ សុទ្ធតែមានតម្លៃសម្រាប់ប្រតិបត្តិក្នុងការដឹកនាំជីវភាពរស់នៅទទួលបានអត្ថប្រយោជន៍អាស្រ័យកាលៈទេសៈ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ លទ្ធិពុទ្ធសាសនាថេរវាទ នៅតែជាលទ្ធិដែលសមស្របនឹងសាកលភាវូបនីយកម្មដែលជឿនលឿនខាងបច្ចេកទេសវិទ្យាសាស្ត្របច្ចុប្បន្ន។ ផ្ទុយទៅវិញការលើកតម្កើងការឃោសនា ជំនឿអ្វីផ្ទុយពីលទ្ធិថេរវាទនេះ វាអាចជានយោបាយដើរថយក្រោយរាប់រយសតវត្សរ៍ ដែលនាំអ្នកទំនាស់ធំធេងរកអ្នកឈ្នះត្រឹមត្រូវមិនឃើញ ដែលនាំឱ្យបរិស័ទដែលក្មេងខ្ចីដ៏ច្រើនលើសលប់វង្វេងធម៌ ព្រោះតែគ្រូធម៌មិនបានបញ្ជាក់ថាខ្លួនកំពុងពន្យល់ទ្រឹស្តីធម៌ក្នុងលទ្ធិពុទ្ធសាសនាណាមួយណាឱ្យពិតប្រាកដ។ ទាំងអស់នេះ គឺជាការទទួលខុសត្រូវរួមរបស់ជាតិសាសន៍ខ្មែរទាំងមូលសម្រាប់ជម្រើសប្រកបដោយវិចារណា។*

**ឯកសារយោង/គន្ថនិទ្ទេស**


១-ធឹង ផាន់សុផុន, *ព្រះសមណគោតម មហាសាស្ត្រាចារ្យនៃមនុស្សនិងទេវតា*, អាម៉េរិក, ១៩៩៥
២-ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧
៣-ត្រឹង ង៉ា, ប្រវត្តិសាស្ត្រខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣
៤-ពុទ្ធសាសនបណ្ឌិត្យ, ព្រះរាជពិធីទ្វាទសមាស, បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ១៩៦៩
៥-វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, *ព្រះត្រៃបិដកបាលីនិងសេចក្តីប្រែជាភាសាខ្មែរ*, ភ្នំពេញ, ពស.២៤៩៧
៦-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)